# រឿងទី៥ ៖ ម៉ូសេ២

ខគម្ពីរ៖
និក្ខមនំ៣៖១០

ឥឡូវនេះ យើងចាត់អ្នកឲ្យទៅជួបស្តេចផារ៉ោន។ ចូរទៅនាំជនជាតិអ៊ីស្រាអែល ជាប្រជារាស្ត្ររបស់យើងចេញពីស្រុកអេស៊ីប។

ម៉ូសេបានធំធាត់ឡើងនៅក្នុងវាំង ម៉ូសេបានក្លាយជាមនុស្សពេញវ័យ។

ម៉ូសេឈឺចាប់ជាខ្លាំងពេលឃើញជនជាតិអ៊ីស្រាអែលដែលកំពុងរស់ជាទាសករ រងការធ្វើទុក្ខទោស ពីជនជាតិអេស៊ីប។

មានថ្ងៃមួយ ម៉ូសេបានដើរឆ្លងកាត់កន្លែងជនជាតិអេស៊ីបធ្វើការ។

មានសាសន៍អេស៊ីបម្នាក់ បានវាយធ្វើបាបសាសន៍ហេព្រើរយ៉ាងសាហាវយង់ឃ្នង។

កាលម៉ូសេឃើញសាសន៍អេស៊ីបវាយធ្វើបាបសាសន៍ហេព្រើរដែលជាញាតិខ្លួនដូច្នេះ គាត់ខឹងសម្បារជាខ្លាំង។

គាត់ក៏បានសម្លាប់សាសន៍អេស៊ីបនោះនៅនឹងកន្លែងនោះតែម្តង។ ដំណឹងថាម៉ូសេបានសម្លាប់សាសន៍អេស៊ីបក៏លេចឮពេញក្នុងវាំង។

កាលស្តេចផារ៉ោនបានឮដំណឹងនោះភ្លាម ក៏រកម៉ូសេដើម្បីសម្លាប់។

ម៉ូសេបានរត់គេចពីពួកទាហានរបស់ស្តេចផារ៉ោនដែលមកតាមចាប់ខ្លួនគាត់ ទៅឯទីវាលរហោស្ថានម៉ាឌាន។

ម៉ូសេបានរស់នៅទីនោះធ្វើជាអ្នកគង្វាលចៀម។

ម៉ូសេបានភ្លេចអស់ពីឋានៈរបស់ខ្លួនដែលធ្លាប់ជាបុត្រានៃស្រុកអេស៊ីប ព្រមទាំងជនជាតិអ៊ីស្រាអែលទាំងអស់ដែល កំពុងជួបទុក្ខលំបាកក្នុងជីវិតជាទាសករនៅស្រុកអេស៊ីប។

មានថ្ងៃមួយ ម៉ូសេបានឡើងទៅឃ្វាលចៀមនៅលើភ្នំហូរ៉ែប។

នៅទីនោះ គាត់បានប្រទះឃើញហេតុការណ៍ដ៏ចម្លែកមួយ។

ពេលនោះ ស្រាប់តែព្រះសូរសៀងរបស់ព្រះជាម្ចាស់ក៏បន្លឺឡើង។

ម៉ូសេភ័យខ្លាចជាខ្លាំង ក៏យកដៃខ្ទប់មុខហើយឱនក្រាបចុះ។

«ម៉ូសេអើយ យើងបានទតឃើញពីការឈឺចាប់ដែលរាស្ត្រយើងកំពុងរងទុក្ខនៅក្នុងស្រុកអេស៊ីប យើងបានស្តាប់ឮ សម្រែកនៃការឈឺចាប់ និងទុក្ខវេទនារបស់ពួកគេ ពេលនេះ យើងនឹងឱ្យអ្នកចេញទៅជួបនិងស្តេចផារ៉ោន ហើយដឹកនាំរាស្ត្រយើងចេញពីស្រុកអេស៊ីប។

ពេលម៉ូសេស្តាប់ឮភ្លាម គាត់ភ័យខ្លាចជាខ្លាំង។

ភ្លាមនោះ ព្រះជាម្ចាស់ក៏មានបន្ទូលថាទ្រង់នឹងគង់នៅជាមួយម៉ូសេ។



ហើយទ្រង់ក៏ត្រៀមអើរ៉ុនជាបងប្រុសគាត់ដែលជាមនុស្សពូកែនិយាយឱ្យទៅជាមួយគាត់។
ហើយម៉ូសេ និងអើរ៉ុនក៏ធ្វើដំណើរចេញទៅស្ដេចផារ៉ោននៅក្នុងស្រុកអេស៊ីប។
ម៉ូសេបាននិយាយទៅស្ដេចផារ៉ោនថា៖ «សូមទ្រង់អនុញ្ញាតឱ្យប្រជារាស្ដ្រអ៊ីស្រាអែលទាំងអស់ចេញទៅទីវាលរហោស្ថានដើម្បីថ្វាយយញ្ញបូជាដល់ព្រះជាម្ចាស់»។
ដោយផារ៉ោនស្ដេចស្រុកអេស៊ីប មានចិត្តចង់ទុករាស្ដ្រអ៊ីស្រាអែលធ្វើជាទាសកររហូត ទ្រង់មិនអនុញ្ញាត ឱ្យពួកគេចេញទៅទេ។
ហើយថែមទាំងធ្វើបាបឱ្យជនជាតិអ៊ីស្រាអែលធ្វើការកាន់តែធ្ងន់ជាងមុនទៀត។ ព្រះជាម្ចាស់ទ្រង់ក្រោធយ៉ាងខ្លាំង។
ដូច្នេះ ព្រះជាម្ចាស់ក៏ធ្វើឱ្យទឹកទន្លេទាំងអស់នៅស្រុកអេស៊ីបប្រែទៅជាឈាម។
ធ្វើឱ្យពួកសាសន៍អេស៊ីបគ្មានទឹកសម្រាប់បរិភោគ។ ប៉ុន្តែ ស្ដេចផារ៉ោននៅតែមិនស្ដាប់តាមដដែល។
ដូច្នេះ ព្រះជាម្ចាស់ក៏ធ្វើឱ្យស្រុកអេស៊ីបទទួលរងនូវគ្រោះកាចជាច្រើនទៀត មានដូចជា គ្រោះកាចកង្កែប ចៃ រុយ ជំងឺអាសន្នរោគ ជំងឺបូស ព្រិល កណ្ដូប ភាពងងឹតអន្ធការ...។
យ៉ាងនេះក្ដី ស្ដេចផារ៉ោន នៅតែមិនព្រមឱ្យរាស្ដ្រអ៊ីស្រាអែលចេញទៅដែរ។ ដូច្នេះ ទីបំផុត ព្រះជាម្ចាស់ក៏ធ្វើឱ្យមានគ្រោះកាចទីដប់កើតមានក្នុងស្រុកអេស៊ីប។
គ្រោះកាចទីដប់ បានធ្វើឱ្យកូនច្បងក្នុងស្រុកអេស៊ីបស្លាប់ទាំងអស់។
សូម្បីបុត្រាច្បងរបស់ស្ដេចផារ៉ោនក៏ត្រូវស្លាប់ដែរ។
ស្ដេចផារ៉ោនគ្មានជំរើសអ្វីក្រៅពី អនុញ្ញាតឱ្យរាស្ដ្រអ៊ីស្រាអែលចាកចេញនោះទេ។
ទីបំផុត រាស្ដ្រអ៊ីស្រាអែលទាំងអស់ បានចាកចេញពីស្រុកអេស៊ីបជាមួយម៉ូសេ។

- សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញ។ (និក្ខមនំ៣៖១០)

ចូរទៅនាំជនជាតិអ៊ីស្រាអែល ជាប្រជារាស្ដ្ររបស់យើងចេញពីស្រុកអេស៊ីប។



**សកម្មភាពទី១** សូមកាត់ និងបិទក្រដាសពណ៌ ដើម្បីបង្កើតជាគុម្ពោតដែលកំពុងឆេះ។ (សម្ភារៈ ក្រដាសពណ៌, កាវ)



**សកម្មភាពទី២** សូមគិតអំពីខ្លឹមសារមេរៀនដែលបានរៀនថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។

